គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ
បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា
Regulate, Supervise, and Develop Trust Sector
in the Kingdom of Cambodia

និយ័តករបរធនបាលកិច្ច
Trust Regulator

លេខ ៨ ចេញផ្សាយថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២១
No. 8 Released on August 23, 2021

អត្ថបទប្រចាំសប្តាហ៍ | Weekly Article

# អត្ថប្រយោជន៍សម្រាប់បរធនបាលទាយក និងអត្ថគាហកៈ | Benefits for Trust Creator and Beneficiary



រូបភាព | Picture: https://mediacloud.kiplinger.com/image/private/s--KhjX8PRK--/f_auto,t_primary-image-

យោងតាមច្បាប់ស្តីពីបរធនបាលកិច្ច (២០១៩) បរធនបាលកិច្ចត្រូវបានបង្កើតឡើងដោយមានការចូលរួមពីភាគីសំខាន់ចំនួន ៣ គឺ បរធនបាលទាយក, បរធនបាល, និងអត្ថគាហកៈ ព្រមទាំងអាចមានភាគីចូលរួមផ្សេងទៀត។ តាមរយៈការបង្កើតបរធនបាលកិច្ច បរធនបាលទាយក និងអត្ថគាហកៈនៃបរធនបាលកិច្ចនឹងទទួលបានផលប្រយោជន៍ រួមមាន៖ **(១)** សិទ្ធិរបស់បរធនបាលទាយក ឬអ្នកផ្តល់វិភាគទានបរធនបាលកិច្ច ក្នុងការរៀបចំ ចាត់ចែង និងផ្ទេរទ្រព្យសម្បត្តិរបស់ខ្លួនតាមសណ្តាប់ធ្នាប់ជាសាធារណៈទៅឱ្យអត្ថគាហកៈ តាមគោលបំណងដែលខ្លួនចង់បាន ដោយមានការគ្រប់គ្រង និងចាត់ចែងត្រឹមត្រូវដោយបរធនបាល ដែលទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតដោយនិយ័តករបរធនបាលកិច្ច (ន.ប.ធ) ដើម្បីជាប្រយោជន៍ដល់អត្ថគាហកៈ។ **(២)** ការការពារបរធន ឬទ្រព្យសម្បត្តិដែលបានផ្ទេរចូលក្នុងបរធនបាលកិច្ច ដោយអនុលោមតាមលិខិតបរធនបាលកិច្ច ឬបទប្បញ្ញត្តិជាធរមាន ប្រកបដោយសណ្តាប់ធ្នាប់ របៀបរៀបរយជាសាធារណៈ ដោយមានអាជ្ញាធរមានសមត្ថកិច្ចច្បាស់លាស់ ក្នុងការការពារសិទ្ធិ និងអត្ថប្រយោជន៍ជាអតិបរមាដល់ម្ចាស់ទ្រព្យ ឬ បរធនបាលទាយក និងអ្នកទទួលផល ឬអត្ថគាហកៈ។ **(៣)** អត្ថគាហកៈ មានសិទ្ធិទទួលផលប្រយោជន៍ពេញលេញពីបរធនបាលកិច្ច ដោយអនុលោមតាមលិខិតបរធនបាលកិច្ច ឬបទប្បញ្ញត្តិជាធរមាន និងទៅតាមគោលបំណងរបស់បរធនបាលទាយក។ សិទ្ធិ និងកាតព្វកិច្ចរបស់បរធនបាលទាយក, បរធនបាល, និងអត្ថគាហកៈ មានចែងលម្អិតនៅក្នុងច្បាប់ស្តីពីបរធនបាលកិច្ច (២០១៩)។

According to the Law on Trust (2019), a trust is created with the participation of three main parties: the trust creator, the trustee, and the beneficiary, as well as other parties. Through the creating of trust, the trust creator and the beneficiary of the trust will receive the following benefits: **(1)** the rights of the trust creator or contributor of the trust to organize, manage, and transfer the asset in public order to the beneficiary for the purpose for which it is desired, under the proper management and administration by the trustee, which is granted license by the Trust Regulator (TR) for the benefit of the beneficiary. **(2)** the protection of the asset transferred into the trust in accordance with the trust instrument or the regulations in force in an orderly manner, public order, with clear authority to protect the maximum rights and interests of the asset owner or trust creator and the beneficiary. **(3)** The beneficiary has rights to receive the full benefits of the trust in accordance with the trust instrument or the regulations in force and in accordance with the purpose of the trust creator. The rights and obligations of the trust creator, the trustee, and the beneficiary are detailed in the Law on Trust (2019).

**អត្ថបទ៖ វង្ស សេនពិសិដ្ឋ | Article: VONG Senpiseth**

**ឯកសារយោង | References**:

- ច្បាប់ស្តីពីបរធនបាលកិច្ច. (២០១៩).

ប្រកាសបដិសេធ៖ ទស្សនៈនៅក្នុងអត្ថបទនេះជាទស្សនៈរបស់អ្នកនិពន្ធ។ ទស្សនៈនៅក្នុងអត្ថបទនេះមិនមែនជាទស្សនៈរបស់និយ័តករបរធនបាលកិច្ចទេ។
Disclaimer: The opinions expressed in this article are those of the authors. They do not purport to reflect the opinions or views of the Trust Regulator.

គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យបរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា
Regulate, Supervise, and Develop Trust Sector
in the Kingdom of Cambodia

និយ័តករបរធនបាលកិច្ច
Trust Regulator

លេខ ៨ ចេញផ្សាយថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២១
No. 8 Released on August 23, 2021

# អត្ថបទប្រចាំសប្តាហ៍ | Weekly Article

ប្រកាសបដិសេធ÷ ទស្សនៈនៅក្នុងអត្ថបទនេះជាទស្សនៈរបស់អ្នកនិពន្ធ។ ទស្សនៈនៅក្នុងអត្ថបទនេះមិនមែនជាទស្សនៈរបស់និយ័តករបរធនបាលកិច្ចទេ។
Disclaimer: The opinions expressed in this article are those of the authors. They do not purport to reflect the opinions or views of the Trust Regulator.

www.facebook.com/trustregulatorcambodia
អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh